**UNITED NATIONS**
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

# សន្និសិទ

# ស្តីពី

# ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិក្នុងប្រទេសកម្ពុជា

# " កត្តាសំខាន់ៗ និង ការអនុវត្តន៍គោលការណ៍ទីក្រុងប៉ារីស "

**សេចក្តីថ្លែងការណ៍ដោយ**

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

**ខេត្តសៀមរាប កម្ពុជា**

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សូមស្វាគមន៍ ចំពោះឱកាសដែលបានផ្តល់ឱ្យនៅក្នុង " សន្និសិទស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា " ដើម្បីធ្វើការពន្យល់អំពីគោលការណ៍ទីក្រុងប៉ារីស និងដើម្បីគូសបញ្ជាក់ពីសារៈសំខាន់នៃការគោរពតាមបទដ្ឋានអន្តរជាតិដែលត្រូវបានទទួលស្គាល់ នៅពេលរៀបចំបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយឯករាជ្យ និងដែលអាចជឿទុកចិត្តបាន។

ស្ថាប័នសិទ្ធិមនុស្សជាតិនៅក្នុងការងាររបស់ខ្លួន ត្រូវបានណែនាំដោយ " គោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិ " ដែលស្គាល់ជាទូទៅថាជាគោលការណ៍ទីក្រុងប៉ារីស ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងឆ្នាំ១៩៩៣។ គោលការណ៍ទាំងនេះ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយចាប់តាំងពីពេលនោះមក ហើយត្រូវតែប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងនេះ។ យោងតាម គោលការណ៍ទាំងនេះ ស្ថាប័នសិទ្ធិមនុស្សជាតិមួយត្រូវមានសមត្ថភាពដើម្បីលើកស្ទួយ និងការពារសិទ្ធិទាំងអស់ រួមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច សិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ និង សិទ្ធិនយោបាយ។ គោលការណ៍នេះ បានកំណត់នូវលក្ខណៈវិនិច្ឆ័យសំខាន់ៗចំនួនប្រាំមួយរួមមាន :

- ធានាឯករាជ្យភាព ដោយលក្ខន្តិកៈដោយឡែក ឬរដ្ឋធម្មនុញ្ញ
- ស្វ័យភាពពីរដ្ឋាភិបាល
- ពហុភាព រួមទាំងពហុភាពនៃសមាជិកភាព
- អាណត្តិទូលំទូលាយ ផ្អែកលើបទដ្ឋានសិទ្ធិមនុស្សជាសកល
- ធនធានគ្រប់គ្រាន់ និង
- អំណាចគ្រប់គ្រាន់ក្នុងការស៊ើបអង្កេត

ដូច្នេះ ស្ថាប័នជាតិនេះ ត្រូវមានអាណត្តិទូលំទូលាយ និងមានន័យជាក់លាក់ ផ្អែកលើលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ហើយមានវិសាលភាពគ្រប់ដណ្តប់លើទឹកដី និក្រុមសង្គមទាំងមូល។ អាណត្តិរបស់ស្ថាប័ននេះ ត្រូវតែចែងឱ្យបានច្បាស់នៅក្នុងអត្ថបទរដ្ឋធម្មនុញ្ញ ឬអត្ថបទច្បាប់ ដោយបញ្ជាក់ពីសមាសភាព និង ដែនសមត្ថកិច្ចរបស់ស្ថាប័ននេះ។ ច្បាប់របស់ស្ថាប័ននេះ គួរត្រូវបានព្រាងឡើងដោយមានការពិគ្រោះយោបល់ជាចំហ និង មានតម្លាភាព រួមទាំងជាមួយសង្គមស៊ីវិល។

ប្រភេទនៃស្ថាប័នសិទ្ធិមនុស្សជាតិ មានលក្ខណៈប្លែកៗគ្នា ពីគណៈកម្មការសិទ្ធិមនុស្សជាតិ និងអំប៊ុតមិនទៅស្ថាប័នឯកទេសផ្សេងៗទៀត ដែលមានមុខងារការពារសិទ្ធិនៃក្រុមមនុស្សមួយចំនួន ដូចជាស្ត្រី ជនជាតិដើមភាគតិច ជនភាគតិច និងកុមារ។

មនុស្សគ្រប់រូបត្រូវមានសិទ្ធិប្រាស្រ័យទាក់ទងជាមួយស្ថាប័នជាតិនេះ ជាពិសេសក្រុមមនុស្សដែលងាយរងគ្រោះបំផុត រួមទាំងជនពិការ និង ជន ដែលមិននិយាយភាសាផ្លូវការ។ ទីកន្លែងធ្វើការអព្យាក្រិត្យមួយ ដែលបុគ្គលគ្រប់រូប ពីគ្រប់មជ្ឈដ្ឋាននៅទូទាំងប្រទេស ដោយរួមទាំងជនទាំងឡាយដែលស្ថិតក្នុងកន្លែងឃុំឃាំងផង យល់ថាអាចចូលជួបប្រាស្រ័យទាក់ទងការងារបាន គឺជាបញ្ហាសំខាន់បំផុត។

នៅពេលមានការស្នើសុំពីសមាជិករបស់ខ្លួន រដ្ឋាភិបាល ឬអ្នកធ្វើញត្តិ ដោយមិនចាំបាច់បញ្ជូនទៅអាជ្ញាធរថ្នាក់លើ ស្ថាប័នជាតិនេះត្រូវដាក់ជូន (តាមគោលការណ៍ផ្តល់យោបល់) ដើម្បីសុំយោបល់ អនុសាសន៍ ឬរបាយការណ៍ពីរដ្ឋាភិបាល ឬសភាជាតិ ស្តីពីបញ្ញត្តិច្បាប់ ឬរដ្ឋបាល ក៏ដូចជាស្ថានភាពជាក់លាក់ពីសិទ្ធិមនុស្ស។ សំណើរទាំងនេះអាចត្រូវបានបោះពុម្ពផ្សាយតាមរយៈមតិសាធារណៈ ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងៗ។

ស្ថាប័នជាតិនេះ ត្រូវបានរំពឹងថានឹងមានភារកិច្ចធានាការលើកស្ទួយ សុខុដុមនីយកម្ម និង ការអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពនៃច្បាប់ជាតិ អោយស្របតាមលិខិតុបករណ៍អន្តរជាតិនានា ។ ស្ថាប័នជាតិនេះត្រូវជំរុញឱ្យមានការផ្តល់សច្ចាប័ន និងការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជាចូលរួមចំណែករៀបចំរបាយការណ៍របស់រដ្ឋភាគី ។

ស្ថានប័នជាតិត្រូវសហការយ៉ាងជិតស្និទ្ធ និងយ៉ាងទៀងទាត់ជាមួយអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល រួមទាំងតាមរយៈគណៈកម្មាធិការប្រឹក្សាយោបល់នានា ។ ស្ថាប័ននេះ ត្រូវបង្កើតទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល សភាជាតិ និងតុលាការ និងចូលរួមក្នុងយន្តការអន្តរជាតិ ដូចជាស្ថាប័នសន្ធិសញ្ញានានា និងមន្ត្រីកាន់កិច្ចការអាណត្តិនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ព្រមទាំងជាមួយបណ្តាញថ្នាក់អន្តរជាតិ និងថ្នាក់តំបន់នៃស្ថាប័នសិទ្ធិមនុស្សជាតិ ។

ស្ថាប័នជាតិនេះ ត្រូវបានគេរំពឹងថា មានភារកិច្ចលើកស្ទួយវប្បធម៌ និងការអប់រំសិទ្ធិមនុស្ស ដើម្បីធានាការបណ្តុះបណ្តាលមន្ត្រីសាធារណៈ រួមទាំងកងកំលាំងសន្តិសុខ ដើម្បីពង្រឹងសមត្ថភាពក្នុងការស្រាវជ្រាវ ការចងក្រងឯកសារ និងការបណ្តុះបណ្តាលជាមួយរដ្ឋាភិបាល សភាជាតិ តុលាការ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ព្រមទាំងយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមមនុស្សដែលងាយរងគ្រោះបំផុត ហើយជាទូទៅត្រូវប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើង និងការប្រកាន់ពូជសាសន៍ ។

ស្ថាប័នជាតិនេះមានអាណត្តិត្រូវលើកស្ទួយ និងការពារសិទ្ធិមនុស្សគ្រប់រូប ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និង សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលរួមទាំងអំណាចទទួល និងស៊ើបអង្កេតបណ្តឹងជាបុគ្គល និងបណ្តឹងជាប្រព័ន្ធ បើកសវនាការជាសាធារណៈ និងធ្វើការស៊ើបសួរ ពិនិត្យកន្លែងឃុំឃាំងទាំងអស់  ដោយគ្មានការយល់ព្រមជាមុន ផ្តល់សេវាប្រឹក្សាយោបល់ រួមទាំង ជួយដល់ស្ថាប័នអនុវត្តន៍ច្បាប់ និងសន្តិសុខ ជួយសំរាលជាបណ្តោះអាសន្នតាមការចាំបាច់ ហើយត្រូវមានអំណាចខ្ពស់ ប្រសិនបើមានការស្នើសុំឱ្យជួយដោះស្រាយករណីរំលោភសិទ្ធិមនុស្ស ដែលគ្មានអ្នកណាចាត់ការបញ្ជូនរឿងក្តីទាំងនោះទៅតុលាការ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធិភាព ។

សមាសភាពរបស់ស្ថាប័នសិទ្ធិមនុស្សជាតិ និងការតែងតាំងសមាជិករបស់ខ្លួន ត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត បើពុំនោះទេ ត្រូវធានាឱ្យមានតំណាងពហុភាពនៃកំលាំងសង្គមនៃសង្គមស៊ីវិល ដូចជាតំណាងអង្គការក្រៅរដ្ឋាភិបាល សហជីព អង្គការសង្គមយុវជន និងអង្គការវិជ្ជាជីវៈនានាដែលពាក់ព័ន្ធ (រួមទាំងមេធាវី វេជ្ជបណ្ឌិត អ្នកកាសែត និងអ្នកវិទ្យាសាស្ត្រផ្សេងៗ) មាននិន្នាការទៅរកគំនិតខាងទស្សនះវិជ្ជា ឬសាសនា សកលវិទ្យាល័យ និងអ្នកជំនាញការនានា ព្រមទាំងសភាជាតិ ។ តំណាងក្រសួងមន្ទីររដ្ឋាភិបាលគួរចូលរួមតែក្នុងពេលពិនិត្យសំរេច ក្នុងសមត្ថភាពជាអ្នកផ្តល់យោបល់តែប៉ុណ្ណោះ ។

ដើម្បីធានាឯករាជ្យភាពក្នុងការប្រតិបត្តិការ ហិរញ្ញវត្ថុ និងការងាររបស់ខ្លួនពីរដ្ឋាភិបាល ត្រូវផ្តល់ឱ្យស្ថាប័នជាតិនេះនូវធនធានគ្រប់គ្រាន់អាចជួលបុគ្គលិក និងទីតាំងសំរាប់ដំណើរការការងាររបស់ខ្លួន ។ ស្ថាប័ននេះត្រូវគ្រប់គ្រងមូលនីធិផ្ទាល់ខ្លួន ទោះជាមានការលៃបំរុងថវិកាពីសភាជាតិ ដោយគ្មានអន្តរការី កំណត់អាទិភាពផ្ទាល់ខ្លួន ដោយផ្អែកលើអាណត្តិតាមផ្លូវច្បាប់របស់ខ្លួន ទទួលខុសត្រូវចំពោះសភាជាតិ តាមរយៈរបាយការណ៍ និងសវនកម្មប្រចាំឆ្នាំ ព្រាងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន និងធ្វើការជ្រើសរើសបុគ្គលិកតែបុគ្គលិកណាដែលមានភក្តីភាពចំពោះស្ថាប័នខ្លួនប៉ុណ្ណោះ ។

កិច្ចដំណើរការជ្រើសរើសប្រធានស្ថាប័ន (ឥស្សរះជនល្បីឈ្មោះដែលគេទទួលស្គាល់) និងសមាជិករបស់ខ្លួន ត្រូវមានតម្លាភាព និងមានការចូលរួមដោយកំណត់លក្ខខណ្ឌច្បាស់លាស់ ។ លក្ខណៈវិនិច្ឆ័យសំរាប់ការជ្រើសរើស រួមមានការបង្ហាញពីបទពិសោធន៍ខាងការងារសិទ្ធិមនុស្ស គ្មានលិខិតថ្កោលទោសកន្លងមក  ប្រជាពលរដ្ឋទទួលស្គាល់ថា អាចជឿទុកចិត្តបាន មានសេចក្តីសុចរិត និងមិន

លំអៀង មិនមាននិន្នាការក្នុងគណបក្សនយោបាយណាមួយ នៅក្នុងអំឡុងពេលនៃការកាន់មុខតំណែង មានតុល្យភាពខាងយេនឌ័រ និង បែកចែកទៅតាមតំបន់ភូមិសាស្ត្រ ។ បុគ្គលិកស្ថាប័ននេះត្រូវមានសមាសភាពជាពហុភាព ឆ្លើយតបទៅគ្រប់ជ្រុងជ្រោយនៃសង្គម ។

ដើម្បីធានាអាណត្តិមួយដែលមានស្ថេរភាពសំរាប់សមាជិកនៃស្ថាប័ននេះ ការតែងតាំងសមាជិកទាំងនេះ ត្រូវធ្វើឡើងដោយបញ្ញត្តិច្បាប់មួយជាផ្លូវការ ដែលកំណត់រយៈពេលមួយជាក់លាក់នៃអាណត្តិដែលអាចបន្ត ប៉ុន្តែត្រូវធានាឱ្យមានពហុភាពនៃសមាជិកភាពរបស់ស្ថាប័ននេះ ។ ការបញ្ឈប់សមាជិក និងបុគ្គលិកជាទូទៅ ត្រូវធ្វើឡើងតាមគោលការណ៍វិសាមញ្ញ និងមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ជាសត្យានុម័ត ។ ការជ្រើសរើស និង និយាមការងាររបស់បុគ្គលិក ត្រូវកំណត់ដោយស្ថាប័ននេះ អាណត្តិ និងលក្ខខណ្ឌផ្សេងៗទៀតត្រូវចែងឱ្យបានច្បាស់នៅក្នុងច្បាប់មួយ ។

ស្ថាប័នជាតិនេះត្រូវមានទំហំសមល្មម ដែលមានសមាជិកបំពេញការងារពេញម៉ោង ( ត្រូវចែងនៅក្នុងច្បាប់របស់ខ្លួន) ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធិភាពខ្ពស់ ។ ស្ថាប័ននេះត្រូវប្រជុំយ៉ាងទៀតទាត់ ហើយប្រសិនជាចាំបាច់ ត្រូវមានវត្តមានសមាជិកទាំងអស់របស់ខ្លួន ។

ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ទាមទារឱ្យមានឆន្ទៈនយោបាយ ការអត់ធ្មត់ ការតស៊ូស្វិតស្វាញ ការជឿជាក់ និងការលះបង់ដាច់ខាតក្នុងការគោរពគោលការណ៍ទីក្រុងប៉ារីស ។ ប្រសិនបើការនេះធ្វើបានត្រឹមត្រូវ ហើយបានបង្កើតបរិយាកាសងាយស្រួលនោះ នឹងអាចផ្តល់កំណើតឱ្យស្ថាប័នមួយដែលអាចជឿទុកចិត្តបាន ជាស្ថាប័នមួយដែលអាចត្រូវបានគេឃើញថាជាស្ថាប័នបន្ថែមប្រសិទ្ធភាពថែមទៀតដល់ស្ថាប័នរដ្ឋដទៃទៀត ផ្តល់ប្រឹក្សាយោបល់ជំនាញឯករាជ្យ រួមទាំងការប្តេជ្ញាចិត្តជាអន្តរជាតិរបស់រដ្ឋ និងផ្តល់ ការស្វែងរកយុត្តិធមិឱ្យជនទាំងឡាយដែលងាយរងគ្រោះបំផុត ។

ក្រៅពីបទដ្ឋានអប្បរមានៃគោលការណ៍ទីក្រុងបារីស ស្ថាប័នសិទ្ធិមនុស្សជាតិដ៏មានប្រសិទ្ធភាពមួយតម្រូវឱ្យមានបរិយាកាសជួយជ្រោមជ្រែងដល់ការងាររបស់ស្ថាប័ននេះ ។ ចាំបាច់ត្រូវមានឆន្ទៈនយោបាយនៅក្នុងរដ្ឋាភិបាល ប្រព័ន្ធតុលាការមួយដែលមានប្រសិទ្ធភាព និងឯករាជ្យ ហើយនិងស្ថាប័នប្រជាធិបតេយ្យផ្សេងៗទៀត និងត្រូវមានការចូលរួមពីសង្គមស៊ីវិល និងការិយាធិបតេយ្យនិយិតកម្ម និងមានការចូលរួមផងដែរពីកងកម្លាំងយោធា និង នគរបាល ។ សមាជិក និង បុគ្គលិកនៃស្ថាប័ននេះ ត្រូវមានឆន្ទៈលើកតម្លៃសិទ្ធិមនុស្ស ហើយនិងមានបទពិសោធន៏ និងគុណសម្បត្តិសមស្រប ក្នុងការបំពេញការងារវិស័យសិទ្ធិមនុស្ស ។ ការដឹកនាំដ៏រឹងមាំ និង ការគ្រប់គ្រងល្អ នៃស្ថាប័ននេះ គឺជាការសំខាន់ចំបាច់ណាស់ ។ ជាទីបញ្ចប់ ស្ថាប័នសិទ្ធិមនុស្សជាតិដ៏មានប្រសិទ្ធិភាពតម្រូវឱ្យមានការយល់ដឹងជាទូទៅ និងការទទួលស្គាល់ទៅលើអាណត្តិតែមួយគត់របស់ស្ថាប័ននេះ ដែលទាក់ទងទៅនឹងរដ្ឋាភិបាល អង្គនីតិបញ្ញត្តិ ស្ថាប័នតុលាការ និង អង្គការសង្គមស៊ីវិល ដែលស្ថាប័នទាំងអស់នេះគឺជាផ្នែកមួយនៃប្រព័ន្ធជាតិសំរាប់ការពារ និងលើកស្ទួយវិស័យសិទ្ធិមនុស្ស ។

ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានបទពិសោធន៏ទូលំទូលាយក្នុងការចូលរួមបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យជាច្រើននៅទូទាំងពិភពលោក រួមទាំងតាមរយៈការផ្តល់យោបល់ផ្នែកច្បាប់ និងត្រៀមខ្លួនជាស្រេច ក្នុងការធ្វើការងារជាមួយប្រទេសកម្ពុជា ដើម្បីឈានទៅសម្រេចអោយបានគោលដៅនេះ ។